ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

# ត្រូវតែមានវប្បធម៌ថ្មីក្នុងការបោះឆ្នោតថ្នាក់ភូមិ

សេរីទើបជាការត្រឹមត្រូវ ។

យោងតាមសេចក្តីថ្លែងការណ៍របស់ក្រសួងមហាផ្ទៃចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៥ អ្នកនាំពាក្យក្រសួងនេះបានថ្លែងថា "ភូមិមិនមែនជាថ្នាក់រដ្ឋបាលឃុំសង្កាត់ដែលបានចែងក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ទេ" ។ ដូច្នេះអ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី យល់ថា ការជ្រើសរើសប្រធាន-អនុប្រធាន និងសមាជិកភូមិ ត្រូវតែឲ្យមានភាពខុសប្លែកពីការជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលតម្រូវឲ្យគណបក្សនីមួយៗចូលរួមដាក់បេក្ខជនរបស់ខ្លួនចូលប្រកួតការបោះឆ្នោតឃុំ-សង្កាត់ ដែលនឹងប្រព្រឹត្តទៅរៀងរាល់៥ឆ្នាំម្តងនោះ ។

ការអនុញ្ញាតឲ្យមានការឈរឈ្មោះជាឯកតត្តនាមនៅថ្នាក់ភូមិ នឹងជួយឲ្យប្រជារាស្ត្រអាចជ្រើសរើសតំណាងភូមិរបស់ខ្លួនបានត្រឹមត្រូវ ជាមនុស្សសកម្មក្នុងការបំរើផលប្រយោជន៍អ្នកភូមិ ព្រោះប្រជាពលរដ្ឋក្នុងភូមិរមែងស្គាល់មនុស្សល្អ មនុស្សសកម្មនៅក្នុងភូមិរបស់ខ្លួនផ្ទាល់ ។

*រាជធានីភ្នំពេញ*, ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥
**ក្រុមអ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី**

*ព័ត៌មានបន្ថែម សូមទាក់ទងការិយាល័យព័ត៌មាន:*
*លោក ស៊ីរិទ្ធី ដួងហាក់ : ០១២ ៨០២ ៧៥៣*

វិថីសុធារស សង្កាត់ចតុមុខ ខណ្ឌដូនពេញ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៧ ៧៦៨ ទូរសារ: (៨៥៥-២៣) ២១៧ ៧៦៩